៥. សេវាបង្កកំណើតដោយសិប្បនិម្មិត
៦. ការព្យាបាលដោយខ្លួនឯង
៧.ការព្យាបាល ឬវះកាត់ដើម្បីជាប្រយោជន៍នៃការកែលម្អផ្នែកណាមួយនៃរាង្គកាយ
៨. ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត និងការព្យាបាលដោយកាំរស្មីឡាស៊ែ
៩. ការព្យាបាលញៀនសុរា និងផ្តាច់គ្រឿងញៀន
១០. ការព្យាបាលអសមត្ថភាពផ្តល់កំណើត
១១. ការវះកាត់ដោយដាក់គ្រាប់ភ្នែកសិប្បនិម្មិត
១២. ការវះកាត់បេះដូង និងសរសៃឈាមបេះដូង
១៣. ការលាងឈាម
១៤. ការព្យាបាលមហារីកដោយសារធាតុគីមី

**ករណីដូចបានរៀបរាប់ខាងលើនេះ ប.ស.ស មិនទូទាត់ចំណាយជូនមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀង ឬទូទាត់សំណងជូនជនរងគ្រោះ ឬអ្នកតំណាងឡើយ។**

**II. ក្នុងករណីសង្គ្រោះបន្ទាន់ តើសេវាដែលមិនរាប់បញ្ចូលក្នុងរបបថែទាំសុខភាពត្រូវបានទូទាត់ចំណាយជូនមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀង ឬទូទាត់សំណងជូនជនរងគ្រោះ ឬអ្នកតំណាងដែរឬទេ?**

ក្នុងករណីសង្គ្រោះបន្ទាន់សេវាដូចមានចែងខាងលើត្រូវបានផ្តល់ជូនសមាជិក **ប.ស.ស** ក្នុងករណីនេះ **ប.ស.ស** ត្រូវទទួលទូទាត់ចំណាយជូនមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងទៅតាមប្រភេទករណីសង្គ្រោះបន្ទាន់។ ចំពោះសមាជិក **ប.ស.ស** ប្រើប្រាស់សេវាសង្គ្រោះបន្ទាន់ក្រៅពីមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងនោះ **ប.ស.ស** នឹងទូទាត់សំណងជូនជនរងគ្រោះ ឬអ្នកតំណាងទៅតាមប្រកាសអន្តរក្រសួងលេខ១៧៣ ក.ប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភាឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព។

# បេឡាជាតិរបបសន្តិសុខសង្គម
# National Social Security Fund

**ជំហានទី២**
**២០១៧**

## ផ្នែកថែទាំសុខភាព



**សម្រាប់ព័ត៌មានទាក់ទងនឹង ប.ស.ស**

- គេហទំព័រ : www.nssf.gov.kh
- Facebook : www.facebook.com/nssfpage
- សារអេឡិចត្រូនិច : hotline@nssf.gov.kh
- លេខទូរស័ព្ទព័ត៌មានបន្ទាន់ : **1286** (24ម៉ោង/7ថ្ងៃ)
- មជ្ឈមណ្ឌលទទួលទូរស័ព្ទ(call Center) : **023 882 434** អាចហៅចូលបាន ៣០នាក់ ក្នុងពេលតែមួយ (24ម៉ោង/7ថ្ងៃ)

**សេចក្តីណែនាំ:**

I. អ្នកត្រូវរក្សាទុក(Save) លេខទូរស័ព្ទ **1286** សម្រាប់អន្តរាគមន៍បន្ទាន់ តែប៉ុណ្ណោះ និងលេខ **023 882 434** ដើម្បីសាកសួរព័ត៌មាន និងសុំអន្តរាគមន៍បន្ទាន់។

II. នៅក្នុងគេហទំព័រ និង Facebook Page មានព័ត៌មានជាច្រើនមានជាអាទិ៍:
   ១. លិខិត បទដ្ឋានគតិយុត្តរបស់ ប.ស.ស ទាំងអស់
   ២. មន្ទីរពេទ្យដែល ប.ស.ស ចុះកិច្ចព្រមព្រៀងទាំង ២៥ខេត្តក្រុង
   ៣. លេខទូរស័ព្ទភ្នាក់ងារ ប.ស.ស សម្រាប់មន្ទីរពេទ្យធំៗ
   ៤. លេខទូរស័ព្ទរបស់មន្ទីរពេទ្យ និងរថយន្តសង្គ្រោះបន្ទាន់
   ៥. ព័ត៌មានផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការងារ ប.ស.ស

## ការផ្ដល់សេវាប្រភេទជំងឺរ៉ាំរ៉ៃ

**I. តើប្រភេទជំងឺរ៉ាំរ៉ៃណាខ្លះ ដែល ប.ស.ស កំណត់សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ ព្រមទាំងប្រើប្រាស់តែឱសថសារវន្ត?**

ដើម្បីធានាបាននូវការផ្ដល់សេវា របបថែទាំសុខភាពសម្រាប់កម្មករនិយោជិត ដែលស្ថិតនៅក្រោមច្បាប់ស្ដីពីការងារ និងបានចុះបញ្ជិកាផ្នែកថែទាំសុខភាពក្នុង ប.ស.ស មូលដ្ឋានសុខាភិបាលសាធារណៈដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស** , កម្មករនិយោជិត និងអ្នកពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តតាមប្រកាសលេខ ២៣៨ ក.ប/ប្រ.ក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ ស្ដីពី ការកំណត់បញ្ជីជំងឺរ៉ាំរ៉ៃនៅក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព គឺការផ្ដល់សេវាពិគ្រោះជំងឺក្រៅ និងសម្រាកពេទ្យ ហើយប្រើប្រាស់តែឱសថសារវន្ត ដែលមាននៅក្នុងមូលដ្ឋាន សុខាភិបាលសាធារណៈប៉ុណ្ណោះ។

ចំពោះឱសថក្រៅពីឱសថសារវន្តជាបន្ទុករបស់សមាជិក **ប.ស.ស** ផ្ទាល់ ដែល ប្រភេទជំងឺរ៉ាំរ៉ៃទាំងនេះ មានជាអាទិ៍៖

១. ជំងឺខ្សោយបេះដូង (Cardiac Failure)
២. ជំងឺសាច់ដុំបេះដូង (Cardiomyopathy)
៣. ជំងឺរលាកថ្លើមប្រភេទបេរ៉ាំរ៉ៃ (Chronic Hepatitis **B**)
៤. ជំងឺរលាកថ្លើមប្រភេទសេរ៉ាំរ៉ៃ (Chronic Hepatitis **C**)
៥. ជំងឺតម្រងនោមរ៉ាំរ៉ៃ (Chronic renal disease)
៦. ជំងឺក្រិនថ្លើម (Cirrhosis of the liver)
៧. ជំងឺសរសៃឈាមក្រហមបេះដូង (Coronary artery disease)
៨. ជំងឺទឹកនោមផ្អែមប្រភេទទី ១ និងទី ២ (Diabetes mellitus Type **1 & 2**)
៩. ជំងឺវិបត្តិចង្វាក់បេះដូង (Dysrhythmias)
១០. ជំងឺក្រិនសរីរាង្គ (Multiple Sclerosis)
១១. ជំងឺវិកលចរិក (Schizophrenia)
១២. ជំងឺលុយពុស (Systemic lupus erythematous)
១៣. ជំងឺលើសឈាម (Hypertension)
១៤. ជំងឺតាឡាសេមី (Thalassemia)

**II. ក្នុងករណីសង្គ្រោះបន្ទាន់ ប្រភេទជំងឺរ៉ាំរ៉ៃដូចបានកំណត់ខាងលើ តើឱសថក្រៅពីឱសថសារវន្តជាបន្ទុករបស់សមាជិក ប.ស.ស ទៀតដែរឬទេ?**

ក្នុងករណីសង្គ្រោះបន្ទាន់ ប្រភេទជំងឺរ៉ាំរ៉ៃដូចបានកំណត់ខាងលើត្រូវបានផ្ដល់ជូនសមាជិក **ប.ស.ស** ទាំងឱសថសារវន្ត និងទាំងឱសថក្រៅពីឱសថសារវន្ត ជាបន្ទុករបស់មូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស** ក្នុងករណីនេះ **ប.ស.ស** ត្រូវទទួលទូទាត់ចំណាយជូនមូលដ្ឋានសុខាភិបាលទៅតាមប្រភេទករណីសង្គ្រោះបន្ទាន់។ ចំពោះសមាជិក **ប.ស.ស** ប្រើប្រាស់សេវាសង្គ្រោះបន្ទាន់ក្រៅពីមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងនោះ **ប.ស.ស** នឹងទូទាត់សំណងជូនជនរងគ្រោះ ឬអ្នកតំណាង ទៅតាមប្រកាសអន្តរក្រសួងលេខ ១៧៣ ក.ប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្ដីពីយន្តការទូទាត់ថ្លៃសេវា ផ្នែកថែទាំសុខភាព។

## សេវាមិនរាប់បញ្ចូលក្នុងរបបថែទាំសុខភាព

**I. តើសេវាមិនរាប់បញ្ចូលក្នុងរបបថែទាំសុខភាពមានអ្វីខ្លះ?**

ដើម្បីធានាបាននូវការផ្ដល់សេវា របបថែទាំសុខភាពសម្រាប់កម្មករនិយោជិត ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ និងបានចុះបញ្ជិកាផ្នែក ថែទាំសុខភាពក្នុង ប.ស.ស មូលដ្ឋានសុខាភិបាលសាធារណៈ, កម្មករនិយោជិត និងអ្នកពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តតាមប្រកាសលេខ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្ដីពីតារកាលិកថែទាំសុខភាព ដែលមានចែងអំពីសេវាមិនរាប់បញ្ចូលក្នុងសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ ដែលសេវាទាំងនេះមានជាអាទិ៍៖

១. ការព្យាបាលដោយមិនគិតថ្លៃដែលមានចែងនៅក្នុងគោលនយោបាយសុខាភិបាលសាធារណៈ
២. ការថែទាំធ្មេញ (ការសំអាតធ្មេញ ការប៉ះធ្មេញ និងការដាក់ធ្មេញ)
៣. ការព្យាបាល និងការវះកាត់ប្តូរភេទ
៤. ការផ្សាំ ឬប្តូរសរីរាង្គផ្សេងៗ (ខួរឆ្អឹង តំរងនោម ថ្លើម បេះដូង និងលំពែង...)